UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

OHCHR

# ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR Cambodia) ចោទជាសំណួរអំពីសមិតភាពនៃការសំរេចនាពេលថ្មីៗនេះអំពីពិរុទ្ធភាពក្នុងករណីបរិហាកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិតទៅនឹងបទដ្ឋានអន្តរជាតិស្តីពីសេរីភាពក្នុងការសំដែងមតិ

ថ្ងៃទី5 ខែសីហា ឆ្នាំ២០០៩

ឆ្លើយតបនឹងការសំរេចអំពីពិរុទ្ធភាពក្នុងករណីបរិហាកេរ្តិ៍ដែលបានធ្វើឡើងកាលពីថ្ងៃម្សិលមិញនេះប្រឆាំងនឹងអ្នកស្រី មូរ សុខហួរ តំណាងរាស្រ្តនៃគណបក្សប្រឆាំង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា(OHCHR Cambodia) បានគូសបញ្ជាក់ អំពីសេចក្តីត្រូវការឲ្យមានការលើកកំពស់សិទ្ធិសេរីភាពក្នុងការសំដែងមតិ ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ការសំរេចនៅពេលថ្មីៗបំផុតនេះ គឺជាការសំរេចលើកទីបីហើយក្នុងករណីបរិហាកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត នៅក្នុងអំឡុងពេលជាងមួយខែនេះ ។

កាលពីខែមុន លោក មឿង សុន ប្រធានអង្គការមូលនិធិទ្រទ្រង់អរិយធម៌ខ្មែរ "ម.ទ.អ.ខ" ត្រូវតុលាការកាត់ទោសឲ្យជាប់ពីបទផ្សាយព័ត៌មានមិនពិត និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ២ ឆ្នាំ និងពិន័យជាប្រាក់ ៧ លាន រៀល និងសងជំងឺចិត្តចំនួន ៨ លានរៀល ចំពោះបទអត្ថាធិប្បាយ ដែលលោកបានលើកឡើងអំពីកង្វល់ចំពោះការចាប់តំឡើងប្រព័ន្ធបំភ្លឺថ្មីមួយនៅប្រាសាទអង្គរវត្ត ។

នៅថ្ងៃទី២៦ ខែមិថុនា លោក ហង្ស ចក្រា ចាងហ្វាងកាសែត "*ខ្មែរម្ចាស់ស្រុក*" ដែលមាននិន្នាការទៅរកគណៈបក្សប្រឆាំង ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ ៩ លានរៀល ព្រោះតែអត្ថបទដែលចុះផ្សាយក្នុងកាសែតរបស់គាត់ដែលបានលាតត្រដាងពីអំពើពុករលួយរបស់រដ្ឋាភិបាល ។

មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលជាផ្នែកមួយនៃច្បាប់កម្ពុជា ចែងថា ការរិតត្បិតណាមួយទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បីគោរពសិទ្ធិ និងកត្តិស័ព្ទរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ។ តាមច្បាប់អន្តរ

ជាតិ សេរីភាពក្នុងការបញ្ចេញមតិ អាចត្រូវបានរិតត្បិត តែនៅក្នុងករណីលើកលែងមួយចំនួនប៉ុណ្ណោះ ដែលចាំបាច់បំផុត និងដែលសមាមាត្រទៅនឹងតំលៃដែលការរឹតត្បឹតនោះទាមទារឲ្យការពារ ។ ការកាត់សេចក្តី និងការផ្តន្ទាទោសថ្មីៗនេះ ទំនងជាមិនស្របតាមបទដ្ឋានទាំងនេះទេ ។ ផលប៉ះពាល់យ៉ាងខ្លាំងពីករណីទាំងនេះគឺអាចនាំឲ្យសាធារណជនលែងហ៊ានជជែកពិភាក្សាគ្នាអំពីបញ្ហាដ៏សំខាន់ទាក់ទងនឹងផលប្រយោជន៍សាធារណៈ និងកាត់បន្ថយទីចំហសំរាប់ការអនុវត្តន៍តំលៃស្នូលបំផុតនៃលិទ្ធិប្រជាធិបតេយ្យ គឺសេរីភាពក្នុងការបញ្ចេញមតិ ។

ចំពោះករណីធំៗពីរទៀតយ៉ាងតិចទាក់ទងនឹងបទបរិហាកេរ្តិ៍ ដែលមិនទាន់ជំនុំជំរះនៅឡើយ ការិយាល័យសិទ្ធិមនុស្ស(OHCHR) អំពាវនាវដល់តុលាការកម្ពុជា សូមមេត្តាយកមកពិចារណាទាំងស្រុងចំពោះបទដ្ឋាននៃរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិ នៅពេលធ្វើការពិចារណាកាត់សេចក្តីករណីទាំងនេះ ។

ការិយាល័យសិទ្ធិមនុស្ស(OHCHR) សូមរំលឹកជាថ្មីថា ក្នុងខែកក្កដា ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានណែនាំដល់តុលាការកម្ពុជាទាំងអស់ឲ្យអនុវត្តបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដូចមានចែងក្នុងសន្ធិសញ្ញាទាំងឡាយដែលកម្ពុជាគឺជាភាគី នៅពេលធ្វើការពិចារណាកាត់សេចក្តីករណីបែបនេះ។ ការិយាល័យសិទ្ធិមនុស្ស(OHCHR) បានបញ្ជាក់ថា " ឥឡូវនេះ គឺវាជាការសំខាន់ចាំបាច់ណាស់ ដែលតុលាការរាជធានីភ្នំពេញត្រូវប្រកាន់ខ្ជាប់នូវតួនាទីនេះ" ។